Education
Public Schools

# លិខិតជូនចំពោះមាតាបិតា / អ្នកថែទាំ ទាក់ទិននឹង *Nitbusters: កម្មវិធីឆែកពិនិត្យចៃក្បាលនៅសាលារៀន*

## Letter to parents/carers concerning *Nitbusters: Head lice in schools program*

ឈ្មោះសិស្ស ______________________ ថ្នាក់ ______________
Child's name                                        Class

ថ្ងៃនៃទិវា Nitbusters ______________________
Date of Nitbusters Day

ថ្ងៃបញ្ជូនលិខិតយល់ព្រមមកសាលារៀនវិញ ______________________
Date for return of consent form

លិខិតជូនចំពោះមាតាបិតា / អ្នកថែទាំ

Nitbusters មានគោលបំណងដើម្បីអប់រំសាលារៀន សិស្ស ហើយនិងមាតាបិតាអំពីចៃក្បាល និងរបៀបកំចាត់វាចេញ។

ខ្ញុំសរសេរលិខិតនេះក្នុងគោលបំណងស្នើសុំការអនុញ្ញាតអំពីលោកអ្នក ដើម្បីឲ្យកូនរបស់លោកអ្នកចូលរួមក្នុងទិវា Nitbusters ដែលនឹងរៀបចំឡើងនៅសាលារៀន នៅថ្ងៃដូចបង្ហាញខាងលើនេះ។ ទិវា Nitbusters គឺជាថ្ងៃដែលមាតាបិតាអាចជួយឆែកពិនិត្យ ហើយព្យាបាលកុមារទាំងអស់ដែលមានចៃក្បាល។

កុមារម្នាក់ៗត្រូវបានលើកទឹកចិត្តឲ្យចូលរួម។ កុមារមិនអាចចូលរួមក្នុងកម្មវិធីនេះបានឡើយ ប្រសិនបើគេគ្មានលិខិតយល់ព្រមដែលបានចុះហត្ថលេខារួច ឬគេក៏នឹងពុំទទួលការដាក់ពិន័យក្នុងលំនាំណាមួយ ចំពោះការមិនបានចូលរួមនោះឡើយ។ មាតាបិតា / អ្នកថែទាំ និង / ឬកុមារអាចដកចេញពីការឆែករកមើលនៅពេលណាក៏បានដែរ។ កុមារដែលមិនចូលរួម អាចសិក្សារៀនសូត្រសម្គាល់មើលចៃ និងពងចៃ ហើយនិងវិធីកំចាត់ចៃ និងពងចៃ។

នៅទិវា Nitbusters កុមារម្នាក់ៗដែលចូលរួម នឹងបានទទួលការឆែកពិនិត្យសក់របស់គេ ដើម្បីកំណត់ថាតើមានសកម្មភាពកើតមានចៃក្បាលពាសពេញឬអត់។ មាតាបិតាដែលជាអ្នកជួយ នឹងពាក់ស្រោមដៃកៅស៊ូ ឬស្រោមដៃកៅស៊ូក្រាស់ដែលអាចបោះចោលក្រោយពេលប្រើ សម្រាប់ទាំងដំណើរការឆែកពិនិត្យ និងការព្យាបាល។ ប្រសិនបើគេរកឃើញពងចៃ ឬចៃ ពេលនោះគេនឹងលាបថ្នាំបន្ទន់សក់នៅលើសក់ រួចមកប្រើក្រាសសិតដោយហ្មត់ចត់។ បន្ទាប់ពីប្រើក្រាសសិតសក់ធំដើម្បីសិតរំដោះសក់ជំពាក់ហើយ គេនឹងប្រើស្និតចិតចៃដើម្បីសិតយកចៃ និងពងចៃចេញពីក្បាល។ គេនឹងផ្លាស់ប្តូរស្រោមដៃរវាងការព្យាបាលកុមារម្នាក់ៗ។ ប្រសិនបើក្បាលរបស់កុមារបង្ហាញឲ្យឃើញសញ្ញានៃការកើតមានពាសពេញ ឬការមើលឃើញជាក់ស្តែងនៃដំបៅ ឬការដាច់រលាត់ ឬរោគរលាកស្បែករុាំរ៉ៃ កុមារនឹងមិនបានទទួលការឆែកពិនិត្យក្បាល ឬការព្យាបាលទេ។

នៅពេលបញ្ចប់កម្មវិធី គេនឹងសិតសក់របស់កុមារ ហើយចងឲ្យមានរបៀបរៀបរយឡើងវិញ។ គេនឹងមិនលាងជំរះថ្នាំបន្ទន់សក់ទេ ដោយព្រោះថាកិច្ចការនេះជាការលំបាកដែលធ្វើនៅសាលារៀន។ ថ្នាំបន្ទន់សក់នឹងមិនធ្វើឲ្យខូចសក់ឡើយ ហើយសិស្សអាចលាងជំរះថ្នាំនេះចេញបាននៅពេលទៅដល់ផ្ទះ។

ក្រាសសិតសក់ទាំងអស់ត្រូវបានគេលាងសំអាតរវាងការព្យាបាលនីមួយៗ ដោយត្រាំនៅក្នុងទឹកក្តៅជាមួយសាប៊ូ ហើយលាងជំរះដោយប្រើទឹកក្តៅពីក្បាលម៉ាស៊ីន ដ្បិតអីចៃវាស្លាប់នៅក្រោមកំដៅ 60 អង្សាសេ។

នឹងមានការផ្ញើកូនលិខិតមួយទៅផ្ទះបន្ទាប់ពីការឆែកពិនិត្យចៃរួច ដើម្បីផ្តល់ដំណឹងជូនលោកអ្នកប្រសិនបើគេបានប្រទះឃើញពងចៃ ចៃ ឬទាំងពងចៃ ហើយនិងចៃនៅលើក្បាលរបស់កូនលោកអ្នក។ គ្រប់ទាំងមាតាបិតានឹងបានទទួលប័ណ្ណព័ត៌មានមួយសន្លឹកស្តីអំពីវិធីព្យាបាលចៃក្បាល ទោះបីជាកូនរបស់គេមិនបានចូលរួមនៅក្នុងកម្មវិធីនេះក៏ដោយ។

ដើម្បីឲ្យកម្មវិធី Nitbusters មានជោគជ័យនៅក្នុងសាលារៀនរបស់យើង កុមារម្នាក់គួរតែបានចូលរួម។ ដ្បិតអីប្រសិនបើសិស្សណាម្នាក់មានចៃក្បាល នោះវានឹងឆ្លងទៅសិស្សនៅក្នុងថ្នាក់ទាំងមូល។ សារបណ្តាំដ៏សំខាន់គឺថា ជនណាក៏ដោយក៏អាចឆ្លងចៃបានដែរ ដោយមិនគិតអំពីអាយុ ភេទ និងសាវតាឡើយ។ ការព្យាបាលចាំបាច់ត្រូវធ្វើឡើងតាមមូលដ្ឋានសហគមន៍ និងបន្តជាប់រហូត។

កម្មវិធីនេះទាក់ទិនសហគមន៍សាលារៀនទាំងមូលធ្វើការរួមគ្នាដើម្បីសម្របសម្រួល និងចាត់ចែងទិវា Nitbusters នៅតាមបរិវេណសាលារៀន ក្នុងការប្រឹងប្រែងដើម្បីព្យាបាលរាងកាយសិស្សទាំងមូលចំពោះចៃក្បាលរួមគ្នាក្នុងពេលតែមួយ។ អង្គការមាតាបិតារបស់សាលារៀនរៀបចំឲ្យមានទិវានេះ ដោយផ្តល់អ្នកជំនួយដើម្បីជួយឆែកពិនិត្យ និងព្យាបាលចៃក្បាលសម្រាប់គ្រប់ទាំងកុមារ។ ការឆែកពិនិត្យធ្វើឡើងដោយមាតាបិតា / អ្នកថែទាំដែលជាអ្នកស្ម័គ្រចិត្តតាមថ្នាក់រៀនមួយថ្នាក់ម្តងៗ ដោយចាប់ផ្តើមពីថ្នាក់សិស្សដែលក្មេងជាងគេនៅថ្ងៃសាលា។ កម្មវិធីនេះប្រើស្និតសិតចៃ និងថ្នាំបន្ទន់សក់ជារបៀបដើម្បីព្យាបាលចៃក្បាល ដែលជាការព្យាបាលមួយមានសុវត្ថិភាព ហើយពុំមានជាតិថ្នាំគីមី ទាក់ទិននឹងការកំចាត់ចៃក្បាលតាមរយៈការសិតសក់។

ប្រសិនបើលោកអ្នកយល់ព្រមឲ្យកូនរបស់លោកអ្នកចូលរួមនៅក្នុងទិវា Nitbusters សូមបំពេញលិខិតយល់ព្រមជាភាសាអង់គ្លេស ហើយបញ្ជូនលិខិតនេះទៅសាលារៀនវិញឲ្យបានទាន់ថ្ងៃដូចបង្ហាញនៅខាងលើនេះ។ កុមារម្នាក់ៗត្រូវការលិខិតយល់ព្រមដាច់ដោយឡែកពីគ្នា ដោយមានការចុះហត្ថលេខាពីមាតាបិតា / អ្នកថែទាំ។

ព័ត៌មាននេះសំអាងលើព័ត៌មានដែលបានផ្តល់នៅតាមវ៉ិបសាយរបស់ក្រសួងសុខាភិបាលរដ្ឋ NSW ស្តីអំពី Nitbusters។

KHMER